# ចំណាប់អារម្មណ៍ លោកស្រី ម៉ម ញឹម

## ប្រធានសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា

## "ស្ថានភាពជាក់ស្តែងនៃឧស្សាហកម្មកាត់ដេរកម្ពុជាបន្ទាប់ពីបញ្ចប់ប្រព័ន្ធកូតា"

## ថ្ងៃ អង្គារ៍ ទី ១៤ ខែ មីនា ឆ្នាំ ២០០៦

**សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដែលបានចូលរួមអង្គប្រជុំតុមូលទាំងអស់ជាទីគោរព និង សូមអរគុណដល់ គម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា និង វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ដែលបានអញ្ជើញនាងខ្ញុំឱ្យឡើងមានចំណាប់អារម្មណ៍ក្នុងកិច្ចពិភាក្សាតុមូលនេះ !**

នាឱកាសនេះ តាំងនាមនាងខ្ញុំតំណាងអោយកម្មករនិយោជិត សមាជិក សមាជិកាសហជីព អ្នកដឹកនាំសហជីព កម្មករទាំងអស់ ដែលមាននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន និង រូបខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបញ្ចប់ប្រព័ន្ធកូតានៅកម្ពុជា ។

អស់លោក លោកស្រីជាទីមេត្រី យើងសង្កេតឃើញថានៅចុងឆ្នាំ ២០០៤ រហូតមកពេលនេះ ដោយសហរដ្ឋអាមេរិកបានបញ្ចប់ប្រព័ន្ធអនុគ្រោះ MFA មក កម្មករ កម្មការិនី បានជួបប្រទះការលំបាកយ៉ាងខ្លាំង ដោយសារការមិនគោរពច្បាប់ពីសំណាក់និយោជក ធ្វើឱ្យកម្មករបាត់បង់ភាពលំនឹងនៅកន្លែងការងារ ក៏ដូចជាការបាត់បង់នៅជំនឿក្នុងការការពារសិទ្ធិរបស់ពួកគេដោយមូលហេតុ:

- មានការរើសអើងសហជីព បញ្ឈប់ថ្នាក់ដឹកនាំសហជីព ឬកម្មករមិនសមហេតុផល

- ប្តូរកិច្ចសន្យាមិនកំណត់ថេរវេលា ឱ្យក្លាយទៅជាកិច្ចសន្យាមានថេរវេលាកំណត់ហើយមានរយៈពេលខ្លី

- រោងចក្រភាគច្រើនមានការជួលកម្មករបណ្តែត ឬបណ្តោះអាសន្នរហូត

- កម្មករធ្វើការច្រើនម៉ោងទទួលប្រាក់ឈ្នួលតិច ធ្វើឱ្យជីវភាពរស់នៅរបស់ពួកគេមានការអន់ថយ និងមានសុខភាពស្លេកស្លាំង ។

- ប្រើវិធីសាស្ត្រគំរាមកំហែងមកលើកម្មករ តាមរយៈរូបភាពផ្សេងៗ ដូចជា: ពេលដែលតំណាងកម្មករធ្វើការតវ៉ា និយោជកតែងតែយកលេះថា បិទរោងចក្រ ឬឱ្យលុយដើរចេញ ឬក៏មានបងតូច បងធំ វាយនៅពេលពួកគេចេញពីធ្វើការ

- ក្រុមហ៊ុនតែងតែកំណត់ចំនួនផលិតផលច្រើន ហើយបញ្ចុះតំលៃបុងទាបដោយសំអាងថា អ្នកទិញអោយតំលៃទាបមិនអាចចំណេញបាន

- មិនគោរពសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទោះបីការកាត់សេចក្តីនោះធ្វើឡើងតាមនិតិវិធីច្បាប់ក៏ដោយ

- និយោជកតែងតែប្តឹងសហជីពឡើងទៅតុលាការដោយមិនសមហេតុផល

- បិទរោងចក្រដោយមិនទូទាត់អតីតភាពការងារតាមផ្លូវច្បាប់អោយកម្មករ ដោយយកលេសថាក្ស័យធន ឬគ្មានអ្នកទិញ ។ រហូតមកដល់ពេលនេះ ពុំទាន់មានអង្គការ ឬស្ថាប័ណាមួយជួយអន្តរាគមន៍ឱ្យមានប្រសិទ្ធិភាពនៅឡើយ ។

បើតាមរបាយការណ៏របស់អង្គការ ILO បានបញ្ជាក់ថា ការបិទរោងចក្រមានចំនួនតិចតួច ផ្ទុយទៅវិញរោងចក្រដែលបើកថ្មីរហូតមកដល់ពេលនេះ មានរោងចក្រចំនួន ៥៩ ក្នុងនោះចំនួនកម្មករមិនមានការថយចុះទេ បើយើងប្រៀបធៀបជាមួយឆ្នាំមុនៗដែលមិនទាន់បញ្ចប់កូតាមកពេលបច្ចុប្បន្ននេះ យើងឃើញថា កំណើនកម្មករច្រើនជាងមុន រីឯចំនួនផលិតផលនាំចេញក៏មានច្រើនជាងមុនដែរ និយោជកតែងតែត្អូញត្អែថាមិនចំណេញ ប៉ុន្តែគ្មានឯកសារណាមួយ ពីនិយោជកមកបញ្ជាក់ច្បាស់លាស់ទេ នេះគ្រាន់តែជាមូលហេតុក្នុងការគេចវេស មិនគោរពច្បាប់តែប៉ុណ្ណោះ ។

ចាប់ពីពេលនេះទៅ ខ្ញុំសង្ឃឹមថានិយោជកនឹងសហការជាមួយសហជីពឱ្យមានកេរ្តិ៍ឈ្មោះល្អ ដើម្បីទាក់ទាញអ្នកទិញឱ្យបានច្រើនសំរាប់ប្រទេសកម្ពុជាព្រោះថា ការគោរពច្បាប់ ការសហការ ជាមូលហេតុដ៏សំខាន់ក្នុងការទាក់ទាញអ្នកទិញនិងជាគំរូល្អសំរាប់វិនិយោគដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ ដើម្បីសហការគ្នាបាននិយោជកគ្រប់រូបត្រូវផ្តល់សិទ្ធិដល់សហជីពក្នុងការចរចាជាសមូហភាព ធ្វើអនុសញ្ញារួម ព្រោះសហជីព គឺជាដៃគូដ៏សំខាន់សំរាប់ទាក់ទាញ ។

ជាថ្មីម្តងទៀត តាងនាមនាងខ្ញុំតំណាងឱ្យសហជីពកម្មករ សំណូមពរដល់រាជរដ្ឋាភិបាលជួយជំរុញដល់ភាគីទាំងអស់ឱ្យមានការគោរពច្បាប់ប្រកបដោយប្រសិទ្ធិភាព

- សុំឱ្យមានវេទិការសំរាប់បញ្ចេញមតិរាល់ពេលមាន វិវាទកើតឡើង (ឧ: មានបញ្ហារោងចក្រ (ក) គួរយកសហជីពកម្មកររោងចក្រ (ក) និង និយោជករោងចក្រ (ក)មកចោទឆ្លើយគ្នា ដើម្បីជៀសវាងការចោទប្រកាន់ដាក់កំហុសគ្នាទៅវិញទៅមក)

- សូមឱ្យក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និង ក្រសួងសង្គមកិច្ច យកចិត្តទុកដាក់រាល់ពេលមានវិនិយោគចូលមកកម្ពុជា ត្រូវតែមានលុយតំកល់សំរាប់ទុកដោះស្រាយកម្មករនៅពេលរោងចក្របិទទ្វារ ឬរត់ចោល

-ដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅលើនិយោជកដែលមិនគោរពច្បាប់

-លើកសរសើរពីនិយោជកល្អ ដើម្បីជាគំរូល្អដល់និយោជកដទៃទៀត

-ជំរុញឱ្យមានតុលាការការងារឱ្យបានឆាប់ ដើម្បីងាយស្រួលក្នុងការដោះស្រាយវិវាទដែលពាក់ព័ន្ធទៅ នឹងការងារ ។

ជាទីបញ្ចប់នេះ នាងខ្ញុំសូមគោរពជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ទាំងអស់ដែលមានវត្តមាននៅទីនេះ សូមជួបប្រទះនូវពុទ្ធពរ ទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**